**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៦៩ សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីរៀបចំកម្មវិធី ប្រកួតវាយកូនគោលពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីអបអរសាទរខួបទី៣១ នៃទិវាជ័យជំនះ ៧ មករា ១៩៧៩- ៧ មករា ២០១០ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ នៅខេត្តសៀមរាប

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងតាមការស្នើសុំរបស់ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

www.pheakdeylaw.com

# សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំកម្មវិធីប្រកួតវាយកូនគោល ពានរង្វាន់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអបអរសាទរខួបទី៣១ នៃទិវាជ័យជំនះ ៧ មករា ១៩៧៩- ៧ មករា ២០១០ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ នៅ Siem Reap Lake Golf Club នាខេត្តសៀមរាប ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ប្រធានកិត្តិយស |
| ២-ឯកឧត្តម **លី ធុជ** | ទេសរដ្ឋមន្ត្រី និងជាអគ្គលេខាធិការរង សហព័ន្ធកីឡាវាយកូនគោលកម្ពុជា | ប្រធាន |
| ៣-ឯកឧត្តម **ណូ សម្បុក** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |
| ៤-ឯកឧត្តម **ហេង សុខគង់** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥-ឯកឧត្តម **ប៊ុន ថាឬទ្ធិ** | អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **សត ណារី** | ស្នងការនគរបាលខេត្តសៀមរាប | សមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ម៉ន សាម៉ុន** | មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប | សមាជិក |
| ៨-ឯកឧត្តម **ចៅ ឡាយ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៩-លោក **ជ្រៀវ សេងគង់** | ប្រធាននាយកដ្ឋានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០-លោក **ប៊ូ វណ្ណរិទ្ធ** | មន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- លោក **សុខ វណ្ណសី** | មន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២-Mr. Sammy Chan | | សមាជិក |
| ១៣-Mr. Kelvin NG | | សមាជិក |
| ១៤-លោក Choi Kwang Doek | នាយកចាត់ចែង Siem Reap Lake Golf Club | សមាជិក |

**ប្រការ២:** ក្រុមការងារនេះ មានតួនាទី និងភារកិច្ចដូចតទៅ :

-រៀបចំចាត់ចែងឯកសារ និងលិខិតអញ្ជើញដល់គណៈប្រតិភូ និងកីឡាករចូលរួម

-រៀបចំធ្វើបដា ពាក្យស្លោក សន្និសីទកាសែត និងសេចក្តីជូនដំណឹងពីកម្មវិធីប្រកួត

-រៀបចំបដិសណ្ឋារកិច្ចដល់គណៈប្រតិភូ និងកីឡាករ

-រៀបចំការស្នាក់នៅ និងពិធីជប់លៀងស្វាគមន៍ដល់គណៈប្រតិភូ និងកីឡាករ

-រៀបចំការការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

-រៀបចំទំនាក់ទំនងការផ្សព្វផ្សាយតាមបណ្តាញទូរទស្សន៍នានា

-ទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំដំណើរការកម្មវិធីឱ្យបានរលូន

-រៀបចំចាត់ចែង និងសម្របសម្រួលទីលានទាំងមុនពេលប្រកួត និងក្រោយពេលប្រកួត

www.pheakdeylaw.com

-រៀបចំពិធីករ Laptop Operator, LCD Projector, Screen and Software

-រៀបចំបទបញ្ហា និងជាគណៈកម្មការអាជ្ញាកណ្តាលសម្រាប់ការប្រកួត

-បូកសរុប និងវាយតម្លៃពិន្ទុដល់កីឡាករចូលរួម ។

**ប្រការ៣:** ក្រុមការងារនេះ មានសិទ្ធិបង្កើតអនុក្រុមការងារដើម្បីធ្វើជាជំនួយការតាមការចាំបាច់ ។

**ប្រការ៤:** ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

**ប្រការ៥:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៦

-ឯកសារ-កាលប្បវត្តិ